**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០៣៩ / ប្រក

ថ្ងៃ ព្រហ ១២កើត ខែ ចេត្រ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍ នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជាស្របតាមគន្លង ប្រក្រតីភាពថ្មី

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជាស្របតាមគន្លងប្រក្រតីភាពថ្មី ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងលើកកម្ពស់សុវត្ថិភាពទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ ២.–**

ប្រកាសនេះមានគោលដៅកំណត់អំពីគោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍ នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.–**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការរៀបចំព្រឹត្តិការណ៍ នៅតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.–**

ព្រឹត្តិការណ៍ទេសចរណ៍ សំដៅដល់ដំណើរនៃការរៀបចំការជួបជុំដែលមានគោលបំណងទេសចរណ៍។

**ប្រការ ៥.–**

លក្ខខណ្ឌវាយតម្លៃការអនុវត្តគោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍ នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងដំណាក់កាលការរីករាលដាលនៃជំងឺឆ្លងកូវីដ១៩ ត្រូវបានកំណត់ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

**ប្រការ ៦.–**

ព្រឹត្តិការណ៍ទេសចរណ៍ដែលបំពេញបានលក្ខខណ្ឌកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះនឹងទទួលបានឡាបិលទទួលស្គាល់ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ១៩ ដែលមានគំរូកំណត់ក្នុងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាអ្នកសម្របសម្រួល និងវាយតម្លៃការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើលក្ខខណ្ឌដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ ៧.–**

គោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រ កម្ពុជានេះ ត្រូវបានដាក់ឱ្យអនុវត្តជាកាតព្វកិច្ច។

ករណីការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ដែលមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍នេះ នឹងក្លាយជាកម្មវត្ថុនៃការពិន័យអន្តរកាល ស្របតាមមាត្រា៦៦ នៃច្បាប់ស្តីពីទេសចរណ៍។

**ប្រការ ៨.–**

គោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជានេះ ត្រូវបានដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ហើយអាចនឹងបន្តក្នុងដំណាក់កាលបន្ទទៀតតាមការចាំបាច់។

**ប្រការ ៩.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងសុខាភិបាល
-គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-មន្ទីរទេសចរណ៍រាជធានី ខេត្ត
-សហព័ន្ធទេសចរណ៍កម្ពុជា
-សមាគមសណ្ឋាគារកម្ពុជា
-ដូចប្រការ១០
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

# ឧបសម្ព័ន្ធទី១
## នៃប្រកាសលេខ០៣៩ ប្រក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២
## ស្ដីពី
## គោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍
## នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជាស្របតាមគន្លង
## ប្រក្រតីភាពថ្មី

ដើម្បីចូលរួមដល់ចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ "** សំដៅដល់ការអប់រំ សណ្ដាប់ធ្នាប់ អនាម័យ របៀបរៀបរយ សុវត្ថិភាព និងសុជីវធម៌ក្នុងការផ្ដល់សេវាកម្មទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងការលើកកម្ពស់គុណភាពក្នុងការគ្រប់គ្រងការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងប្រទេស ក៏ដូចជាការពង្រឹងនូវសមត្ថភាពការងារ និងការទទួលខុសត្រូវខ្ពស់របស់ម្ចាស់កម្មវិធីពិសេសចូលរួមចំណែកក្នុងការធ្វើឲ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងកក់ក្ដៅ "Kingdom of Wonder - Feel the Warmth" ជូនភ្ញៀវជាតិ និងអន្តរជាតិស្របតាមបែបបទ និងស្តង់ដារជាធរមាន ក្រសួងទេសចរណ៍សូមធ្វើការណែនាំដល់គ្រប់ភាគីពាក់ព័ន្ធដែលមានបំណងរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងប្រទេស ត្រូវធ្វើការស្នើសុំការអនុញ្ញាត និងសម្របសម្រួលពីក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម ៖

**ផ្នែកទី១- ប្រកចេញចូលកម្មវិធី ឬព្រឹត្តិការណ៍ និងផែនការគ្រប់គ្រងហានិភ័យ**

គោលការណ៍ណែនាំទី ១៖ ភាពសមរម្យរបស់ទីកន្លែងរៀបចំកម្មវិធី ឬព្រឹត្តិការណ៍

គោលការណ៍ណែនាំទី ២៖ ការគិតគូរអំពីច្រកចេញ ចូលកម្មវិធី ឬព្រឹត្តិការណ៍

គោលការណ៍ណែនាំទី ៣៖ ការវាយតម្លៃបឋមលើគម្រោងរៀបចំកម្មវិធី ឬព្រឹត្តិការណ៍

គោលការណ៍ណែនាំទី ៤៖ ផែនការគ្រប់គ្រងហានិភ័យ

គោលការណ៍ណែនាំទី ៥៖ ការគ្រប់គ្រងភាពអាសន្ន

គោលការណ៍ណែនាំទី ៦៖ ការសង្គ្រោះបន្ទាន់

**ផ្នែកទី ២- រៀបចំកម្មវិធី ឬព្រឹត្តិការណ៍នៅតាមអគារសាធារណៈរបស់រដ្ឋ ឬឯកជន**

គោលការណ៍ណែនាំទី ៧៖ លិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន និងម្ចាស់ទីតាំង

គោលការណ៍ណែនាំទី ៨៖ ការរៀបចំវេទិកា ឬកន្លែងទស្សនារបស់ទស្សនិកជន និងស្លាកសញ្ញា

គោលការណ៍ណែនាំទី៩៖ កម្មវិធីសម្ដែង ពិព័រណ៍

**ផ្នែកទី ៣- អ្នកគ្រប់គ្រង សម្របសម្រួល និងវិធានការបង្ការ**

គោលការណ៍ណែនាំទី ១០៖ នីតិវិធីប្រតិបត្តិការ

គោលការណ៍ណែនាំទី ១១៖ វិធានការបង្ការអគ្គីភ័យ

គោលការណ៍ណែនាំទី ១២៖ អ្នកគ្រប់គ្រង និងសម្របសម្រួលកម្មវិធី ឬព្រឹត្តិការណ៍

**ផ្នែកទី ៤- ការគ្រប់គ្រងទស្សនិកជន ឬទេសចរ**

គោលការណ៍ណែនាំទី ១៣៖ ការគ្រប់គ្រងទស្សនិកជន ឬទេសចរ

គោលការណ៍ណែនាំទី ១៤៖ ការគ្រប់គ្រង និងវិធានការសុវត្ថិភាព

គោលការណ៍ណែនាំទី១៥៖ ច្រកសុវត្ថិភាព

**ផ្នែកទី ៥- បញ្ហាទាក់ទងនឹងគ្រឿងញៀន**

គោលការណ៍ណែនាំទី ១៦៖ បម្រាមពាក់ព័ន្ធនឹងគ្រឿងញៀន

គោលការណ៍ណែនាំទី ១៧៖ បម្រាម ឬវិធានការពាក់ព័ន្ធនឹងថ្នាំជក់ ឬបារី

**ផ្នែកទី ៦- ការអប់រំ និងកាត់បន្ថយផលប៉ះពាល់ជុំវិញបរិវេណកម្មវិធី ឬព្រឹត្តិការណ៍**

គោលការណ៍ណែនាំទី ១៨៖ ការអប់រំអំពីទេសចរណ៍ និងទីក្រុងស្អាត

គោលការណ៍ណែនាំទី ១៩៖ ការអប់រំអំពីវិធានការណ៍សុខាភិបាលក្នុងដំណាក់កាលកូវីដ-១៩

គោលការណ៍ណែនាំទី ២០៖ ការគិតគូរអំពីបរិស្ថាន

គោលការណ៍ណែនាំទី ២១៖ ការគ្រប់គ្រងប្រព័ន្ធភ្លើង (Lighting)

គោលការណ៍ណែនាំ ២២៖ ការគ្រប់គ្រងសម្លេង

គោលការណ៍ណែនាំ ២៣៖ ការគ្រប់គ្រងកាំរស្មីឡាស៊ែរ និងកាំជ្រួច

គោលការណ៍ណែនាំទី ២៤៖ ការសម្អាតអនាម័យនិងសំរាម

**ផ្នែកទី ៧ - សេវាសម្ព័ន្ធ**

គោលការណ៍ណែនាំ ២៥៖ បង្គន់អនាម័យនិងការសម្អាត

គោលការណ៍ណែនាំទី ២៦៖ ការផ្គត់ផ្គង់ទឹក

គោលការណ៍ណែនាំទី ២៧៖ ការដំឡើង និងរៀបចំប្រព័ន្ធអគ្គីសនី

គោលការណ៍ណែនាំទី ២៨៖ តូបលក់អាហារបណ្ដោះអាសន្ន



ក្រសួងទេសចរណ៍

| ផ្នែកទី១- ច្រកចេញចូលកម្មវិធី ឬព្រឹត្តិការណ៍ និងផែនការគ្រប់គ្រងហានិភ័យ | | | | |
|---|---|---|---|---|
| **លរ.** | **គោលការណ៍ណែនាំ** | **ការវាយតម្លៃ** | **សេចក្តីពន្យល់** | **សម្គាល់** |
| ១ | ភាពសមរម្យរបស់ទីកន្លែងរៀបចំកម្មវិធី ឬព្រឹត្តិការណ៍ | **ពិនិត្យ៖**<br>- មធ្យោបាយ ធ្វើដំណើរសាធារណៈ<br>- ច្រកដោយឡែកសម្រាប់ក្រុមការងារចេញចូលនិងផ្គត់ផ្គង់សម្ភារៈ<br>- ច្រកសម្រាប់សមត្ថកិច្ច និងសង្គ្រោះបន្ទាន់<br>- អាចឆ្លើយតបនឹងចំនួនទស្សនិកជន និងទេសចរចូលរួម<br>- មិនប៉ះពាល់ដល់បរិស្ថានជុំវិញ សម្លេង ពន្លឺ និងអ្នករស់នៅ ជុំវិញ-ល-)<br>- បន្ទប់ទឹកសមមាត្រ<br>- ចំណតសមមាត្រ | **ការរៀបចំព្រឹត្តិការណ៍ទាមទារចាំបាច់ការជ្រើសរើសទីតាំងដែលមានភាពសាកសមសម្រាប់ការប្រមូលផ្តុំ និងចូលរួមរបស់មហាជន ឬទេសចរ។ ដូច្នេះ ការគិតគូរអំពីមធ្យោបាយធ្វើដំណើរ ច្រកចេញចូល ផែនទីសម្រាប់ការជួបជុំ ឬព្រឹត្តិការណ៍ ការគិតគូរពីបញ្ហាបរិស្ថាន អនាម័យ និងសន្តិសុខ សុវត្ថិភាពរបស់អ្នកចូលរួម និងសម្បទានទ្រទ្រង់នានាជាករណីចាំបាច់បំផុត។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២ | ការគិតគូរអំពីច្រកចេញ ចូលកម្មវិធី ឬព្រឹត្តិការណ៍ | - ច្រកចេញចូលសម្រាប់ជនពិការ<br>- ចំនួនច្រកចេញ ចូលជាក់លាក់ (សម្រាប់អគារ)<br>- ចំណត<br>- សម្រាប់ទីតាំងក្រៅអគារត្រូវបញ្ជាក់ផែនទីច្រកចេញ ចូលដែលបានរៀបចំ និងច្រកបម្រុង។ | **ច្រកចេញ ចូលទូទៅ និងដោយឡែកសម្រាប់ជនពិការត្រូវបានយកចិត្តទុកដាក់។ ក្នុងនោះដែរច្រកបម្រុងករណីមានហានិភ័យកើតឡើងជាកត្តាសត្យានុម័តដែលត្រូវបានគិតគូរ។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| ៣ | ការវាយតម្លៃបឋមលើគម្រោងរៀបចំកម្មវិធី ឬព្រឹត្តិការណ៍ | - វិធានការសន្តិសុខ និងសណ្តាប់ធ្នាប់<br>- ការគិតគូរអំពីមធ្យោបាយសុខាភិបាល<br>- គោលការណ៍ណែនាំសម្រាប់ការចូលរួម | ការវាយតម្លៃបឋម ជាយន្តការត្រួតពិនិត្យអំពីភាពច្បាស់លាស់ និងប្រុងប្រយ័ត្នខ្ពស់របស់អ្នកស្នើសុំរៀបចំព្រឹត្តិការណ៍ដែលអាចធានាបាននូវភាពជោគជ័យគួរជាទីពេញចិត្ត។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៤ | ផែនការគ្រប់គ្រងហានិភ័យ | - កំណត់ហានិភ័យ<br>- វិភាគអំពីហានិភ័យ<br>- វាយតម្លៃហានិភ័យ<br>- ដំណោះស្រាយ | ការរៀបចំព្រឹត្តិការណ៍ត្រូវមានការគិតគូរឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាបានថាហានិភ័យដែលអាចនឹងកើតឡើងក្នុងទ្រង់ទ្រាយតូច និងអាចគ្រប់គ្រងបាន។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៥ | ការគ្រប់គ្រងភាពអាសន្ន | - អគ្គីសនី<br>- អគ្គីភ័យ<br>- ការផ្ទុះ<br>- ភាពចង្អៀតនៃអ្នកចូលរួម<br>- ការប្រែប្រួលអាកាសធាតុ (ភ្លៀងខ្លាំង) | ករណីហានិភ័យកើតឡើង ការឆ្លើយតបត្រូវមានភាពរហ័ស និងទាន់សភាពការណ៍ស្របតាមស្តង់ដាបច្ចេកទេស។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៦ | ការសង្គ្រោះបន្ទាន់ | - សម្ភារសង្គ្រោះបឋម<br>- ចំនួនបុគ្គលិកសង្គ្រោះសមមាត្រនឹងការជួបជុំ ឬព្រឹត្តិការណ៍<br>- បុគ្គលិកសង្គ្រោះត្រូវមានវិញ្ញាបនបត្រទទួលស្គាល់ពីសុខាភិបាល | ភាពចាំបាច់ក្នុងការធានា និងគ្រប់គ្រងហានិភ័យត្រូវផ្តោតលើយន្តការនៃការសង្គ្រោះបឋមដែលអាចដោះស្រាយបញ្ហាដែលនឹងកើតមានបានទាន់ពេលវេលា។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | **ផ្នែកទី ២- រៀបចំកម្មវិធី ឬព្រឹត្តិការណ៍នៅតាមអគារសាធារណៈរបស់រដ្ឋ ឬឯកជន** | | | |

| | | | | |
|---|---|---|---|---|
| ៧ | លិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន និងម្ចាស់ទីតាំង | - លិខិតអនុញ្ញាតចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ឬម្ចាស់ទីតាំងឯកជន | **ការរៀបចំព្រឹត្តិការណ៍ត្រូវមានការទទួលស្គាល់ ពីស្ថាប័ន និងរដ្ឋបាលមូលដ្ឋាន។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៨ | ការរៀបចំវេទិកា ឬកន្លែងទស្សនារបស់ទស្សនិកជន និងស្លាកសញ្ញា | - ចំនួនកៅអី ឬគំលាតអប្បរមាសម្រាប់អ្នកចូលរួម<br>- ច្រកចេញ សមមាត្រនឹងចំនួនអ្នកចូលរួម<br>- ស្លាកសញ្ញាច្រកចេញករណីអគ្គិភ័យ | **ដើម្បីផ្តល់ភាពងាយស្រួលការរៀបចំត្រូវស្របតាមបទដ្ឋាន ណែនាំ ដើម្បីធានាបានការគ្រប់គ្រង និងលំហូរអ្នកចូលរួម។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ៩ | កម្មវិធីសម្តែងពិព័រណ៍ | - កម្មវិធីលម្អិត | **កម្មវិធីលម្អិតត្រូវបានរៀបចំរួចរាល់ដើម្បីធ្វើការចាត់តាំងអ្នកគ្រប់គ្រង និងទទួលខុសត្រូវតាមផែន។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| **ផ្នែកទី ៣- អ្នកគ្រប់គ្រង សម្របសម្រួល និងវិធានការបង្ការ** | | | | |
| ១០ | នីតិវិធីប្រតិបត្តិការ | - ច្រកចេញ ចូលសម្រាប់អ្នករៀបចំ និងក្រុមការងារ<br>- ចំណត<br>- ច្រកចូលផ្លូវការ<br>- ផែនទីលំហូរចូលព្រឹត្តិការណ៍<br>- ផែនការគ្រប់គ្រងភាពចង្អៀតក្នុងព្រឹត្តិការណ៍<br>- ផែនការសង្គ្រោះបន្ទាន់ | **ការអនុវត្តត្រូវមាននិតីវិធីច្បាស់លាស់ដើម្បីធានាភាពជោគជ័យក្នុងការរៀបចំព្រឹត្តិការណ៍។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ១១ | វិធានការបង្ការអគ្គិភ័យ | - បំពង់ពន្លត់អគ្គីភ័យ<br>- សម្ភារពន្លត់អគ្គីភ័យតាមស្តង់ដារអគារ | **ករណីអគ្គីភ័យអាចនឹងកើតមានជាយថាហេតុនៅគ្រប់ការជួបជុំ ឬព្រឹត្តិការណ៍។ ដូច្នេះ វិធានការបង្ការជាយន្តការដែលមិនអាចខ្វះ។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| | | - គ្រប់សម្ភារបង្ការ និងពន្លត់អគ្គីភ័យត្រូវមានសុពលភាពតាមការកំណត់របស់ស្ថាប័នបន្លត់អគ្គីភ័យ | | |
| ១២ | អ្នកគ្រប់គ្រង និងសម្របសម្រួលកម្មវិធី ឬព្រឹត្តិការណ៍ | - ចំនួនបុគ្គលិកសមមាត្រនឹងព្រឹត្តិការណ៍ ភារកិច្ច និងការទទួលខុសត្រូវ<br>- ទីតាំងមេសម្រាប់ទំនាក់ទំនងអ្នកគ្រប់គ្រង និងរៀបចំ (ងាយស្រួលក្នុងការទំនាក់ទំនង)<br>- មធ្យោបាយទំនាក់ទំនងអ្នករៀបចំ និងបុគ្គលិក | ការកំណត់អត្តសញ្ញាណអ្នកគ្រប់គ្រង និងសម្របសម្រួលអាចផ្តល់ភាពងាយស្រួលក្នុងការម្ចាស់ការលើព្រឹត្តិការណ៍។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | **ផ្នែកទី ៤- ការគ្រប់គ្រងទស្សនិកជន ឬទេសចរ** | | |
| ១៣ | ការគ្រប់គ្រងទស្សនិកជន ឬទេសចរ | - ផែនការលំហូរចូលព្រឹត្តិការណ៍<br>- ចំនួនអ្នកចូលរួមមិនត្រូវហួសចំនួនទទួលយកនៃទីតាំង ដោយអនុវត្តការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងសមត្ថភាពផ្ទុកតាមគន្លងប្រក្រតីភាពថ្មី<br>- វីដេអូ និងឧបករណ៍បំពងសម្លេងសម្រាប់ការណែនាំពេលមានការកកស្ទះ | លំហូរអ្នកចូលរួមត្រូវបានយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងលើការ កកស្ទះ ឬហានិភ័យជាយថាហេតុ។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ១៤ | ការគ្រប់គ្រង និងវិធានការសុវត្ថិភាព | - បុគ្គលិកទទួលខុសត្រូវលើកាមេរ៉ាសុវត្ថិភាព<br>- ត្រួតពិនិត្យភាពមិនប្រក្រតីរបស់អ្នកចូលរួម<br>- បុគ្គលិកត្រួតពិនិត្យសំបុត្រ<br>- បុគ្គលិកសន្តិសុខ<br>- បម្រាមដើម្បីធានាសន្តិសុខ និងសណ្តាប់ធ្នាប់ | អត្តសញ្ញាណអ្នកទទួលខុសត្រូវតាមមុខសញ្ញាជាភាពចាំបាច់សម្រាប់ការគ្រប់គ្រងការជួបជុំ ឬព្រឹត្តិការណ៍។ | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| ១៥ | ច្រកសុវត្ថិភាព | - ច្រកចេញ ចូលមានភាពងាយស្រួល និងអាចមើលឃើញ<br>- ច្រកចេញ ចូលគួរមានទទឹងអប្បរមា ២,៥០ ម៉ែត្រ | **ករណីមានហានិភ័យណាមួយកើតឡើង ការត្រៀមច្រកសុវត្ថិភាពអាចជួយដោះស្រាយបញ្ហាបានយ៉ាងប្រសើរ។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| **ផ្នែកទី ៥ - បញ្ហាទាក់ទងនឹងគ្រឿងញៀន** | | | | |
| ១៦ | បម្រាមពាក់ព័ន្ធនឹងគ្រឿងញៀន | - បម្រាមពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន<br>- សារអប់រំពីផលប៉ះពាល់ដែលបង្កឡើងដោយគ្រឿងញៀន | **ការហាមឃាត់ និងអប់រំអំពីគ្រឿងញៀនត្រូវបានយកចិត្តទុកដាក់បំផុតក្នុងកំឡុងពេលព្រឹត្តិការណ៍។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ១៧ | បម្រាម ឬវិធានការពាក់ព័ន្ធនឹងថ្នាំជក់ ឬបារី | - បម្រាមពាក់ព័ន្ធនឹងថ្នាំជក់ ឬបារី<br>- លិខិតអនុញ្ញាតសម្រាប់អាជីវកម្មថ្នាំជក់ ឬបារី | **ការអប់រំ និងវិធានការនៃការប្រើប្រាស់ថ្នាំជក់ ឬបារីត្រូវអនុវត្តអនុលោមការការណែនាំក្រសួងសុខាភិបាល។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| **ផ្នែកទី ៦- ការអប់រំ និងកាត់បន្ថយផលប៉ះពាល់ជុំវិញបរិវេណកម្មវិធី ឬព្រឹត្តិការណ៍** | | | | |
| ១៨ | ការអប់រំអំពីទេសចរណ៍ និងទីក្រុងស្អាត | - សារអប់រំពីទេសចរណ៍ និងទីក្រុងស្អាត (សមមាត្រនឹងអ្នកចូលរួម) | **ទេសចរណ៍ និងទីក្រុងស្អាតជាការអប់រំមួយដើម្បីធានាបានការចូលរួមក្នុងការកសាង និងអភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ១៩ | ការអប់រំអំពីវិធានការសុខាភិបាលក្នុងដំណាក់កាលកូវីដ-១៩ | - សារអប់រំ និងវិធានការសុខាភិបាល (អនាម័យ សម្អាតដៃឱ្យបានញឹកញាប់ រក្សាគម្លាត និងពាក់ម៉ាស) (សមមាត្រនឹងអ្នកចូលរួម) | **ក្នុងដំណាក់កាលនៃជំងឺឆ្លងកូវីដ១៩ វិធានការបង្ការ ការពារនិងអប់រំជាយន្តការចាំបាច់មិនអាចខ្វះបាន។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២០ | ការគិតគូរអំពីបរិស្ថាន | - សារអប់រំអំពីបរិស្ថាន (សមមាត្រនឹងអ្នកចូលរួម) | **ការចូលរួមក្នុងកិច្ចការពារបរិស្ថានជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |

| | | | | |
|---|---|---|---|---|
| ២១ | ការគ្រប់គ្រងប្រព័ន្ធភ្លើង (Lighting) | - ការគ្រប់គ្រងប្រព័ន្ធភ្លើងតាមស្តង់ដាបច្ចេកទេសដែលមិនប៉ះពាល់ដល់អ្នកជុំវិញ | **ពន្លឺភ្លើងអាចជាការរំខានដល់អ្នករស់នៅជុំវិញការរៀបចំព្រឹត្តិការណ៍។** | □មាន<br>□មិនមាន |
| ២២ | ការគ្រប់គ្រងសម្លេង | - ការគ្រប់គ្រងប្រព័ន្ធសម្លេងតាមស្តង់ដាដែលកំណត់ដោយបទដ្ឋានជាធរមាន | **សម្លេងអាចជាការរំខានដល់អ្នករស់នៅជុំវិញការរៀបចំព្រឹត្តិការណ៍។** | □មានគ្រប់គ្រាន់<br>□មិនមាន |
| ២៣ | ការគ្រប់គ្រងកាំរស្មីឡាស៊ែរ និងកាំជ្រួច | - ការគ្រប់គ្រងកាំរស្មីឡាស៊ែរ និងកាំជ្រួចតាមស្តង់ដាសុវត្ថិភាពរបស់សមត្ថកិច្ច | **កាំរស្មីឡាស៊ែរអាចជាការរំខានដល់អ្នករស់នៅជុំវិញការរៀបចំព្រឹត្តិការណ៍។** | □មានគ្រប់គ្រាន់<br>□មិនមាន |
| ២៤ | ការសម្អាតអនាម័យ និងសំរាម | - សារអប់រំពីការសម្អាតអនាម័យ និងសំរាម<br>- ធុងសំរាមសមមាត្រនឹងអ្នកចូលរួម<br>- ទីតាំងធុងសំរាមដែលងាយមើលឃើញ | **បញ្ហាអនាម័យ និងសំរាមត្រូវមានការគិតគូរខ្ពស់សម្រាប់ការរៀបចំព្រឹត្តិការណ៍។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| | | **ផ្នែកទី ៧- សេវាសម្ព័ន្ធ** | | |
| ២៥ | បង្គន់អនាម័យនិងការសម្អាត | - បង្គន់សមមាត្រនឹងអ្នកចូលរួម<br>- មានអ្នកសម្អាតប្រចាំការក្នុងពេលព្រឹត្តិការណ៍ | **បង្គន់អនាម័យត្រូវបានគិតគូរសម្រាប់ព្រឹត្តិការណ៍ទាំងមូល។** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២៦ | ការផ្គត់ផ្គង់ទឹក | - មានប្រព័ន្ធទឹក និងប្រភពទឹកប្រើប្រាស់សម្រាប់ព្រឹត្តិការណ៍ | **ប្រភពទឹកត្រូវបានគិតគូរសម្រាប់ការរៀបចុះព្រឹត្តិការណ៍** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២៧ | ការដំឡើង និងរៀបចំប្រព័ន្ធអគ្គីសនី | - មានប្រភពផ្គត់ផ្គង់អគ្គីសនី | **ប្រភពអគ្គិសនីត្រូវបានគិតគូរសម្រាប់ការរៀបចំព្រឹត្តិការណ៍** | □មានគ្រប់គ្រាន់<br>□មានមិនគ្រប់គ្រាន់ ឬមិនមាន |
| ២៨ | តូបលក់អាហារបណ្តោះអាសន្ន | - តូបអាហារសម្រន់<br>- តូបលក់ភេសជ្ជៈ | **សេវាហូបចុកត្រូវសមមាត្រនឹងព្រឹត្តិការណ៍** | □មានគ្រប់គ្រាន់ |

| | | | | |
|---|---|---|---|---|
| | | - តូបលក់ និងផ្ដល់សេវាកម្មបន្ទាប់បន្សំផ្សេងៗ | | □មានមិនគ្រប់គ្រាន់ ឬមិនមាន |

# ឧបសម្ព័ន្ធទី២

## នៃប្រកាសលេខ.០៣៩ ប្រក ចុះថ្ងៃទី១៣...ខែ.មេសា..ឆ្នាំ២០២២

## ស្ដីពី

## គោលការណ៍ណែនាំសម្រាប់ការរៀបចំព្រឹត្តិការណ៍
## នៅតាមគោលដៅទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជាស្របតាមគន្លង
## ប្រក្រតីភាពថ្មី

**ឡាបិលទទួលស្គាល់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍**
**ដែលអនុវត្តស្របតាមគោលការណ៍ណែនាំ**

**វិធានសុវត្ថិភាពទេសចរណ៍**
**TOURISM SAFETY MEASURES**

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel